# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

## ជំពូក ១៣

# ប្រពន្ធ័ដាក់ស្លាកសញ្ញាការបោសសម្អាត

~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~


អគ្គលេខាធិការដ្ឋាន

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១| ០២៣-៨៨១-៤៩២

គេហទំព័រ: www.cmaa.gov.kh
~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~

# មាតិកា

**សេចក្តីផ្តើម** ........ 1
**ប្រព័ន្ធដាក់ស្លាកសញ្ញាការបោសសម្អាត** ........ 2
**១.ទ្រង់ទ្រាយ** ........ 2
**២.វាក្យស័ព្ទ និងនិយមន័យ** ........ 2
**៣.លក្ខណៈទូទៅនៃប្រព័ន្ធដាក់ស្លាកសញ្ញា** ........ 2
៣.១ ស្លាកសញ្ញា និង បង្គោល ........ 2
៣.២ ប្រព័ន្ធស្លាកសញ្ញា ........ 3
**៤. បង្គោល និង ប្រព័ន្ធស្លាកសញ្ញា** ........ 3
**៥ ការទទួលខុសត្រូវ** ........ 6
៥.១ អាជ្ញាធរមីន ........ 6
៥.២ ប្រតិបត្តិករ ........ 6
**ឧបសម្ព័ន្ធ ក** ........ 7
**ឧបសម្ព័ន្ធ ខ** ........ 8

## សេចក្តីផ្តើម

ការដាក់ស្លាកសញ្ញាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម រួមទាំងកូនគ្រាប់ គឺត្រូវបានធ្វើឡើងដើម្បីផ្តល់បម្រាម អោយបានច្បាស់លាស់អំពីគ្រោះថ្នាក់ដល់បុរស ស្ត្រី ក្មេងដែលរស់នៅក្នុងតំបន់មានការគំរាមកំហែង។ បើអាចធ្វើបានគួរដាក់របាំងដើម្បីកាត់បន្ថយភាពប្រថុយប្រថានចូលក្នុងតំបន់ មានគ្រោះថ្នាក់ ដោយអចេតនា។

ស្លាកសញ្ញាត្រូវមានលក្ខណៈងាយសម្គាល់ មានភាពជាប់លាប់ និងធ្វើឲ្យអ្នកបម្រុងចូលក្នុងតំបន់នោះអាចមើលឃើញ។

គួរប្រើប្រាស់ស្លាកសញ្ញាហាមប្រាម ដែលសហគមន៍រស់នៅក្នុងតំបន់មានការគំរាមកំហែងបានស្គាល់រួចមកហើយ ដើម្បីដាក់ជាស្លាកសញ្ញា។ ស្លាកសញ្ញា និងបង្គោលដាក់តាមព្រំប្រទល់ធ្វើយ៉ាងណាឲ្យគេអាចអានបាន និងមើលឃើញពីចម្ងាយ ប្រើបានយូរ និងធន់ទៅនឹងបរិយាកាសទូទៅ ហើយងាយដឹងថាខាងណាជាតំបន់គ្រោះថ្នាក់ និងខាងណាជាតំបន់មានសុវត្ថិភាព។

ស្តង់ដានេះបញ្ជាក់អំពីសញ្ញា បង្គោល និងប្រព័ន្ធដាក់ស្លាកសញ្ញា ដើម្បីប្រើប្រាស់ មុនពេល អំឡុងពេល និងក្រោយពេលបោសសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ដែលគេស្គាល់ថាជាប្រព័ន្ធដាក់ស្លាកសញ្ញាការបោសសម្អាត។ ស្តង់ដានេះ មិនពណ៌នាអំពីប្រព័ន្ធដាក់ស្លាកសញ្ញាចម្ការមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដែលមិនមានក្នុងផែនការបោសសម្អាតក្នុងពេលឆាប់ៗឡើយ។ ជាទូទៅចម្ការមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដែលមិនមានក្នុងផែនការបោសសម្អាតក្នុងពេលឆាប់ៗខាងមុខ មិនត្រូវដាក់ស្លាកសញ្ញាទេ ដោយសារបញ្ហាធនធានលក្ខខណ្ឌធម្មជាតិ និងការបាត់បង់ដោយប្រជាជនក្នុងតំបន់។

# ប្រព័ន្ធដាក់ស្លាកសញ្ញាការបោសសម្អាត

## ១.វិសាលភាព

ស្តង់ដារនេះ បញ្ជាក់ពីតម្រូវការអប្បបរមាក្នុងការដាក់ស្លាកសញ្ញាចម្ការមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម រួមទាំងចម្ការកូនគ្រាប់ដែលត្រៀមបោសសម្អាត។ ស្តង់ដារនេះ បញ្ជាក់ពីប្រព័ន្ធដាក់ស្លាកសញ្ញាដែលប្រើប្រាស់ក្នុងអំឡុងពេលប្រតិបត្តិការបោសសម្អាតផងដែរ។ ប្រតិបត្តិករត្រូវរៀបចំបទដ្ឋានប្រតិបត្តិការរបស់ខ្លួនឲ្យស្របទៅតាមតម្រូវការអប្បបរមានៃស្តង់ដារនេះ។

## ២.វាក្យស័ព្ទ និងនិយមន័យ

អក្ខរានុក្រមនៃវាក្យស័ព្ទ និយមន័យ និងពាក្យកាត់ទាំងអស់ដែលបានប្រើនៅក្នុងស្តង់ដារនេះមានពន្យល់ នៅក្នុងជំពូក ៣០។

## ៣.លក្ខណៈទូទៅនៃប្រព័ន្ធដាក់ស្លាកសញ្ញា

ការបង្កើតប្រព័ន្ធដាក់ស្លាកសញ្ញាមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម គួរគិតដល់សម្ភារៈដែលមានស្រាប់នៅក្នុងតំបន់ និងគិតអំពីរយៈពេលនៃការប្រើប្រាស់ប្រព័ន្ធដាក់ស្លាកសញ្ញានៅទីនោះ។ ចំពោះសម្ភារៈដែលត្រូវបានយកមកប្រើប្រាស់ក្នុងប្រព័ន្ធដាក់ស្លាកសញ្ញា គួរតែជាវត្ថុគ្មានតម្លៃ និងមិនអាចយកទៅប្រើប្រាស់ក្នុងបំណងផ្សេងៗបាន។ បើសិនសម្ភារៈដែលត្រូវបានប្រើប្រាស់ទាំងនោះមានតម្លៃ និងអាចយកទៅធ្វើរបស់របរប្រើប្រាស់បាន នោះវាអាចនឹងត្រូវបាត់បង់ដោយសារប្រជាជនរស់នៅក្នុងមូលដ្ឋាន។

### ៣.១ ស្លាកសញ្ញា និង បង្គោល

ស្លាកសញ្ញាគ្រោះថ្នាក់ គឺជាស្លាកសម្គាល់យូរអង្វែង ផ្តល់ព័ត៌មានជាលាយល័ក្ខអក្សរ និងជានិមិត្តសញ្ញា ដែលជាផ្នែកមួយនៃប្រព័ន្ធដាក់ស្លាកសញ្ញា បង្កើតឡើងសម្រាប់ដាក់បម្រាមដល់សហគមន៍អំពីវត្តមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។ គំរូស្លាកសញ្ញាគ្រោះថ្នាក់មានបង្ហាញក្នុងឧបសម្ព័ន្ធ ក។ ការប្រើប្រាស់ពាក្យ គួរបញ្ជាក់ពីអត្ថន័យសំខាន់នៃគ្រោះថ្នាក់ (មីន ឬ សំណល់ជាតិផ្ទុះពីសង្គ្រាម) ហើយនិមិត្តសញ្ញាគួរបង្ហាញពី "គ្រោះថ្នាក់" ក្នុងទម្រង់ងាយសម្គាល់បានជាទូទៅដោយ បុរស ស្ត្រី និងកុមារ។

សញ្ញាសម្គាល់គ្រោះថ្នាក់ យ៉ាងហោចគួរអាចមើលឃើញពីចម្ងាយ៣០ម៉ែត្រនៅពេលថ្ងៃ និងអាចមើលឃើញពីសញ្ញាសម្គាល់មួយទៅសញ្ញាសម្គាល់មួយទៀត។ បើសញ្ញាសម្គាល់គ្រោះថ្នាក់ ត្រូវបាំងដោយសារព្រៃ ឬសណ្ឋានដី គួរពិចារណាប្រើសញ្ញាសម្គាល់គ្រោះថ្នាក់បន្ថែម។

មិនគួរយកសំបកគ្រាប់ សម្ភារៈ ដែលមានជាតិរំសេវផ្ទុះ ឬប្រព័ន្ធសព្វាវុធផ្សេងៗ មកធ្វើជាសញ្ញាសម្គាល់គ្រោះថ្នាក់ឡើយ។

## ៣.២ ប្រព័ន្ធស្លាកសញ្ញា

ក) គួរដាក់ប្រព័ន្ធស្លាកសញ្ញាអោយបានមុនពេលប្រតិបត្តិការបោសសម្អាត (ការដាក់ស្លាកសញ្ញាតាមព្រំប្រទល់) ក្នុងអំឡុងពេលបោសសម្អាត (ការដាក់ស្លាកសញ្ញាប្រតិបត្តិការ) និងក្រោយពេលបញ្ចប់កិច្ចប្រតិបត្តិការបោសសម្អាត (ការដាក់ស្លាកសញ្ញាបញ្ចប់ប្រតិបត្តិការ)។

ខ) ប្រព័ន្ធស្លាកសញ្ញាច្នៃ ជាទូទៅត្រូវបានដាក់ឬប្រើប្រាស់ដោយសហគមន៍មូលដ្ឋាន។ ប្រតិបត្តិករដោះមីន គួរជៀសវាងការប្រើប្រាស់ប្រព័ន្ធស្លាកសញ្ញាច្នៃ។ ប្រព័ន្ធស្លាកសញ្ញាច្នៃដែលដាក់ដោយប្រជាជន គួរត្រូវដាក់ជំនួសដោយប្រព័ន្ធស្លាកសញ្ញាយូរអង្វែងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

គ) ចំពោះដីដែលមានថ្ម ឬទីតាំងណាដែលមិនអាចដំបង្គោលទៅក្នុងដី/ថ្មនោះបាន ត្រូវប្រើវត្ថុសមស្របដែលត្រូវបានលាបថ្នាំពណ៌ក្រហម/ស ឬបាញ់ថ្នាំលើដី/ថ្ម ជំនួសការប្រើប្រាស់បង្គោល។ ត្រូវលុបចោលថ្នាំដែលបានបាញ់លើដី/ថ្មនោះចេញ នៅពេលដែលការបោសសម្អាតត្រូវបានរំកិលទៅមុខ។

ឃ) ជាទូទៅការដាក់ស្លាកសញ្ញារួមមាន ១)ការដាក់ស្លាកសញ្ញាព្រំប្រទល់ ២)ការដាក់ស្លាកសញ្ញាក្នុងអំឡុងពេលប្រតិបត្តិការ ៣)ការដាក់ស្លាកសញ្ញាពេលបញ្ចប់ប្រតិបត្តិការ:

i. ការដាក់ស្លាកសញ្ញាព្រំប្រទល់: គោលបំណងនៃការដាក់ស្លាកសញ្ញាព្រំប្រទល់ គឺដើម្បីកំណត់ទំហំនៃកិច្ចប្រតិបត្តិការបោសសម្អាត។ ជាការប្រសើរ ការដាក់ស្លាកសញ្ញាព្រំប្រទល់គប្បីចាប់ផ្តើមធ្វើ និងបញ្ចប់ឲ្យបានមុនពេលកិច្ចប្រតិបត្តិការបោសសម្អាតចាប់ផ្តើម។ ដោយសារការដាក់ស្លាកសញ្ញាព្រំប្រទល់ត្រូវចំណាយពេលវេលាច្រើន ប្រតិបត្តិករអាចដាក់ស្លាកសញ្ញាព្រំប្រទល់ដំណាលគ្នា និងកិច្ចប្រតិបត្តិការបោសសម្អាតក៏បានដែរ ។

ii. ការដាក់ស្លាកសញ្ញាអំឡុងពេលប្រតិបត្តិការ: គោលបំណងនៃការដាក់ស្លាកសញ្ញាក្នុងអំឡុងពេលប្រតិបត្តិការ គឺដើម្បីចែកឲ្យដាច់ពីគ្នាយ៉ាងច្បាស់រវាងកន្លែងដែលបានបោសសម្អាតរួច និងកន្លែងមិនទាន់បោសសម្អាត និងដើម្បីបង្ហាញប្លង់ការដ្ឋានសម្រាប់កិច្ចប្រតិបត្តិការបោសសម្អាត។

iii. ការដាក់ស្លាកសញ្ញាពេលបញ្ចប់ប្រតិបត្តិការ: គោលបំណងនៃការដាក់ស្លាកសញ្ញាពេលបញ្ចប់ប្រតិបត្តិការ គឺដើម្បីធ្វើកំណត់សម្គាល់ឲ្យបានច្បាស់លាស់ ចំពោះកន្លែងដែលបានបោសសម្អាតរួច។ ការដាក់ស្លាកសញ្ញាពេលបញ្ចប់ប្រតិបត្តិការ អាចធ្វើឡើងដំណាលគ្នា និងកិច្ចប្រតិបត្តិការបោសសម្អាត ឬនៅពេលការបោសសម្អាតត្រូវបានបញ្ចប់។ ការដាក់ស្លាកសញ្ញាពេលបញ្ចប់ប្រតិបត្តិការធ្វើឡើងដើម្បីជាការសម្គាល់នាពេលខាងមុខ។

# ៤. បង្គោល និង ប្រព័ន្ធស្លាកសញ្ញា

កថាខណ្ឌខាងក្រោមពណ៌នាពីទីតាំងដែលត្រូវដាក់ស្លាកសញ្ញា សណ្ឋានបង្គោល និងប្រព័ន្ធស្លាកសញ្ញា:

៤.១ **ចំណុចសម្គាល់ (BM)**: BM ត្រូវសម្គាល់ ដោយប្រើបង្គោលបេតុងទំហំ ១៥សម x ១៥សម ប្រវែង ១៥០សម លាបថ្នាំពណ៌ស។ ប្រតិបត្តិករអាចសរសេរឈ្មោះ ឬសញ្ញាសម្គាល់អង្គការលើបង្គោល BM តាមតម្រូវការ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ១)

៤.២ **ចំណុចចាប់ផ្តើម (SP)**: SP ត្រូវសម្គាល់ដោយប្រើបង្គោលបេតុងទំហំ ១៥សម x ១៥សម ប្រវែង ១៥០សម លាបថ្នាំពណ៌ស និងលាបថ្នាំពណ៌ក្រហមនៅផ្នែកខាងលើប្រវែង ១០សម។ នៅពេលចម្ការមីន/គ្រាប់ត្រូវបានបញ្ចប់ បង្គោលបេតុងនោះត្រូវបានលាបថ្នាំពណ៌សទាំងស្រុង។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ២)

៤.៣ **កន្លែងត្រួតពិនិត្យតំបន់រដ្ឋបាល (CP)**: CP ត្រូវសម្គាល់ដោយប្រើបង្គោលប្រវែង១៥០សម លាបថ្នាំពណ៌សនៅផ្នែកខាងលើប្រវែង២០សម ដាក់តាមរបត់ និងចន្លោះរបត់។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៣)

៤.៤ **តំបន់រដ្ឋបាល**: ត្រូវប្រើបង្គោលប្រវែង៥០សម លាបថ្នាំពណ៌ស ដាក់តាមរណ្តៅកម្ទេចដែក រណ្តៅសំរាម រណ្តៅបំផែកមីន កន្លែងធ្វើតេស្តម៉ាស៊ីន កន្លែងបង្ហាញចម្ការមីន/គ្រាប់សិប្បនិម្មិត ផ្លូវទៅបង្គន់ និងជុំវិញបង្គន់ ផ្លូវទៅឃ្លាំងគ្រឿងផ្ទុះ និងកន្លែងចំណតរថយន្ត ដែលមានចន្លោះពីមួយទៅមួយមិនលើសពី២ម។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៤)

៤.៥ **ឃ្លាំងគ្រឿងផ្ទុះ**: ឃ្លាំងគ្រឿងផ្ទុះ ត្រូវរៀបចំស្ថិតក្នុងចម្ងាយសុវត្ថិភាពពីតំបន់រដ្ឋបាល ប្រើបង្គោលប្រវែង១៥០សម លាបថ្នាំពណ៌ក្រហម/ស/ក្រហម និងភ្ជាប់ដោយសញ្ញាមីន ដាក់តាមគ្រប់ជ្រុងនៃទីតាំង ហើយត្រូវស្ថិតនៅឆ្ងាយផុតពីសម្ភារៈងាយឆាបឆេះ និងអាចសម្គាល់បានច្បាស់។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៥, ៦)

៤.៦ **រណ្តៅបន្សាបមីន**: ត្រូវប្រើបង្គោលប្រវែង១៥០សម លាបថ្នាំពណ៌ក្រហម/ស/ក្រហម និងភ្ជាប់ដោយសញ្ញាមីន ដាក់តាមគ្រប់ជ្រុងនៃទីតាំង។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៥)

៤.៧ **ព្រំប្រទល់ចម្ការមីន/គ្រាប់**: ត្រូវប្រើបង្គោលប្រវែង១៥០សម លាបថ្នាំពណ៌ក្រហម/ស/ក្រហម និងភ្ជាប់ដោយសញ្ញាមីន ដាក់តាមព្រំមានចន្លោះពីមួយទៅមួយមិនលើសពី២៥ម និងតាមគ្រប់របត់។ បើចាំបាច់ គួរដាក់តាមចំណុចចន្លោះដើម្បីអាចឃើញច្បាស់។ ស្លាកសញ្ញាដែលដាក់នៅតាមរបត់ គួរបែរឲ្យឃើញពីជ្រុងទាំងពីរ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៥)

៤.៨ **បរិមាត្រចម្ការមីន/គ្រាប់**: ត្រូវប្រើបង្គោលប្រវែង១៥០សម លាបថ្នាំពណ៌ក្រហម/ស/ក្រហម ដាក់ក្នុងអំឡុងពេលបោសសម្អាតពីមួយទៅមួយចម្ងាយ២៥ម ដោយមានបង្គោលប្រវែង៥០សម លាបថ្នាំពណ៌ក្រហម ពីមួយទៅមួយចម្ងាយមិនលើសពី២ម ដាក់តាមព្រំ ដែលម្ខាងទៀតមានការសង្ស័យ។ ស្លាកសញ្ញា/បង្គោលនឹងត្រូវរំកិលចេញ នៅពេលការបោសសម្អាតត្រូវបានពង្រីក។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៥,៦,៧)

៤.៩ **មុខចាប់ផ្តើមធ្វើការ:** ត្រូវប្រើបង្គោលប្រវែង៥០សម លាបថ្នាំពណ៌ខៀវ ដាក់នៅលើចំណុចចាប់ផ្តើមធ្វើការ ហើយទុកនៅទីនោះរហូតដល់បញ្ចប់ម៉ោងធ្វើការ។ ការប្រើបង្គោលចាប់ផ្តើមអាចអោយយើងវាស់ផ្ទៃដីដែលបានបោសសម្អាតដោយអ្នកដោះមីនប្រចាំថ្ងៃ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ១២)

៤.១០ **មុខធ្វើការ:** ការដាក់ស្លាកសញ្ញា/បង្គោល ក្នុងចន្លោះមុខធ្វើការ មិនឲ្យលើសពី២ម ឬអាស្រ័យលើនីតិវិធីបោសសម្អាតរបស់ប្រតិបត្តិករដែលបានចែងក្នុងបទដ្ឋានប្រតិបត្តិការរបស់គេ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៧)

៤.១១ **មីនដែលបានរកឃើញ:** មីនដែលបានរកឃើញ ត្រូវប្រើបង្គោលប្រវែង៥០សម ដែលភ្ជាប់ដោយសញ្ញាមីន និងបង្គោលប្រវែង៥០សម លាបថ្នាំពណ៌ក្រហមពីរផ្សេងទៀត ដាក់នៅចម្ងាយពីមីន៥០សម។ បង្គោលទាំងបីនេះត្រូវដំចូលក្នុងដីជាជួរមានចន្លោះប្រវែងមិនលើស៣០សម ហើយបង្គោលដែលភ្ជាប់ដោយសញ្ញាមីនត្រូវនៅកណ្តាល។ (សូមមើលឧបសម្ព័ន្ធខ លេខ៧,៨)

៤.១២ **ទីតាំងរកឃើញមីនថ្មើរជើង:** ត្រូវប្រើបង្គោលប្រវែង៥០សម លាបថ្នាំពណ៌លឿង ហើយនៅលើបង្គោលត្រូវសរសេរជាភាសាអង់គ្លេសនូវប្រភេទមីននិងជម្រៅដែលរកឃើញជាសង់ទីម៉ែត្រ។ (សូមមើល ឧបសម្ព័ន្ធ ខ លេខ ៩)

៤.១៣ **ទីតាំងរកឃើញមីនប្រឆាំងរថក្រោះ:** ត្រូវប្រើបង្គោលប្រវែង១០០សម លាបថ្នាំពណ៌លឿង ហើយនៅលើបង្គោលត្រូវសរសេរជាភាសាអង់គ្លេស នូវប្រភេទមីន និងជម្រៅដែលរកឃើញជាសង់ទីម៉ែត្រ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ១០)

៤.១៤ **ទីតាំងរកឃើញសំណល់ជាតិផ្ទុះពីសង្គ្រាម:** ត្រូវប្រើបង្គោលប្រវែង៥០សមពណ៌លឿង/ស ហើយលើបង្គោលត្រូវសរសេរជាភាសាអង់គ្លេស នូវប្រភេទគ្រាប់។ (សូមមើលឧបសម្ព័ន្ធខ លេខ១១)

៤.១៥ **ទីតាំងមិនទាន់បានបោសសម្អាតបណ្តោះអាសន្ន:** នៅពេលមានការចាំបាច់ត្រូវទុកទីតាំងខ្លះមិនបានបោសសម្អាតដែលស្ថិតនៅក្នុងចម្ការមីន/គ្រាប់ ទីតាំងទាំងនោះត្រូវប្រើបង្គោលពណ៌ក្រហមប្រវែង៥០សម ដាក់ចន្លោះពីមួយទៅមួយចម្ងាយ២ម ហើយប្រើបង្គោលប្រវែង១៥០សម នៅតាមជ្រុង ឬតាមរបត់។ នៅពេលបញ្ចប់ការបោសសម្អាត ទីតាំងទាំងនោះត្រូវដាក់ស្លាកសញ្ញាឡើងវិញ ដូចបានបញ្ជាក់ក្នុងការដាក់ស្លាកសញ្ញាក្រោយការបោសសម្អាតរួច។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ៥,៧)

៤.១៦ **ពំនូកដីដែលមានជាតិដែក:** ពំនូកដីដែលមានជាតិដែក(រណ្តៅកំទេចដែក) ត្រូវប្រើបង្គោលពណ៌សប្រវែង៥០សម ដំគម្លាតពីគ្នាមិនលើសពី១ម។ ពំនូកដីដែលមានជាតិដែក ឬ រណ្តៅកំទេចដែកទាំងនោះ ត្រូវរៀបចំក្នុងកន្លែងដែលបានបោសសម្អាតរួច។ (សូមមើល ឧបសម្ព័ន្ធ ខ លេខ៤)

៤.១៧ **ការដាក់ស្លាកសញ្ញាកន្លែងបោសសម្អាតរួច:** នៅពេលបញ្ចប់ការដ្ឋាន ត្រូវប្រើបង្គោលដែកប្រវែង៣០សម បញ្ចុះក្នុងដីជម្រៅ៣០សមផុតពីផ្ទៃដី បើចាំបាច់ត្រូវប្រើបង្គោលបេតុងពណ៌ក្រហម/សផងដែរ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ១៦,២)

៤.១៨ **កន្លែងត្រួតពិនិត្យផ្ទៃក្នុង:** ត្រូវបានប្រើបង្គោលដូចបានបង្ហាញខាងក្រោម:

I. **កន្លែងត្រួតពិនិត្យដោយបុគ្គលិកទីវាលៈ** កន្លែងត្រួតពិនិត្យដោយបុគ្គលិកទីវាល (ប្រធានក្រុម ប្រធានកង ប្រធានការដ្ឋាន) ត្រូវប្រើបង្គោលប្រវែង៥០សមដែលមានលាបថ្នាំពណ៌បៃតង ១០សម ផ្នែកខាងលើ ។ (សូមមើលឧបសម្ព័ន្ធ ខ លេខ ១៣)

II. **កន្លែងត្រួតពិនិត្យដោយបុគ្គលិកភូមិភាគៈ** កន្លែងត្រួតពិនិត្យដោយបុគ្គលិកភូមិភាគ ត្រូវប្រើបង្គោលប្រវែង៥០សម ដែលមានលាបថ្នាំពណ៌បៃតង/ស ១០សម+១០សម ផ្នែកខាងលើ។ (សូមមើល ឧបសម្ព័ន្ធ ខ លេខ ១៤)

III. **កន្លែងត្រួតពិនិត្យដោយបុគ្គលិកទីបញ្ជាការៈ** កន្លែងត្រួតពិនិត្យដោយបុគ្គលិកទីបញ្ជាការ ត្រូវប្រើបង្គោលប្រវែង៥០សម ដែលមានលាបថ្នាំពណ៌បៃតង/ស/ខៀវ ១០សម+១០សម+១០សម ផ្នែកខាងលើ។ (សូមមើល ឧបសម្ព័ន្ធ ខ លេខ ១៥)

## ៥ ការទទួលខុសត្រូវ

### ៥.១ អាជ្ញាធរមីន

អាជ្ញាធរមីត្រូវរៀបចំបង្កើត និងផ្សព្វផ្សាយស្តង់ដាប្រព័ន្ធស្លាកសញ្ញាមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យបានសមស្រប និងអាចយកទៅប្រើប្រាស់បានក្នុងសកម្មភាពមីន ដោយមានការត្រួតពិនិត្យនូវការអនុវត្តន៍ ។

### ៥.២ ប្រតិបត្តិករ

ប្រតិបត្តិករបោសសម្អាតមីនត្រូវបង្កើតបទដ្ឋានប្រតិបត្តិការរបស់ខ្លួន(SOP) ឲ្យស្របតាមតម្រូវការស្តង់ដានេះ។

ប្រតិបត្តិករបោសសម្អាតមីនត្រូវពន្យល់អំពីប្រព័ន្ធស្លាកសញ្ញាដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ រួមមាន បុរស ស្ត្រី និងកុមារ ដែលរស់ក្នុងតំបន់មានការគំរាមកំហែង និងស្នើសុំសហការចូលរួមថែរក្សា និងគោរពប្រព័ន្ធស្លាកសញ្ញា ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៥

**អគ្គលេខាធិការ**

**ព្រំ សុភមង្គល**

## ឧបសម្ព័ន្ធ ក
## សញ្ញាគ្រោះថ្នាក់

**រូបភាព ១: ស្លាកសញ្ញាគ្រាប់មិនទាន់ផ្ទុះ**




ចំណាំ:

១. ស្លាកសញ្ញាគួរប្រើផ្ទៃពណ៌ក្រហម ជាមួយរូបសញ្ញាគ្រោះថ្នាក់ពណ៌ស។ រូបសញ្ញាគ្រោះថ្នាក់ជាសាកលគឺក្បាលខ្មោចនិងឆ្អឹងខ្មោចខ្វែង។

២. ពាក្យ (ប្រយត្ន័គ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះ) ត្រូវបានប្រើពីរភាសា ខ្មែរ និងអង់គ្លេស។

៣. គួរប្រើពណ៌សលើផ្ទៃខាងក្រោយនៃសញ្ញា។

៤. ទំហំសញ្ញាមិនគួរតូចជាងរូបភាពដែលបានបង្ហាញ។

**រូបភាព ២: ស្លាកសញ្ញាមីន**




ចំណាំ:

១. ស្លាកសញ្ញាគួរប្រើផ្ទៃពណ៌ក្រហម ជាមួយរូបសញ្ញាគ្រោះថ្នាក់ពណ៌ស។ រូបសញ្ញាគ្រោះថ្នាក់ជាសាកលគឺក្បាលខ្មោចនិងឆ្អឹងខ្មោចខ្វែង។

២. ពាក្យ (ប្រយត្ន័គ្រោះថ្នាក់មីន) ត្រូវបានប្រើពីរភាសា ខ្មែរ និងអង់គ្លេស។

៣. គួរប្រើពណ៌សលើផ្ទៃខាងក្រោយនៃសញ្ញា។

៤. ទំហំសញ្ញាមិនគួរតូចជាងរូបភាពដែលបានបង្ហាញ

# ឧបសម្ព័ន្ធ ខ

## បង្គោល ( posts, poles, pickets, metal bars )

ក) **បង្គោល/Post:** ១៥០សម x ១៥សម x ១៥សម ធ្វើពីបេតុង លាបថ្នាំពណ៌ស ៥០សម ពីផ្ទៃដី ហើយលាបថ្នាំពណ៌ក្រហមនៅផ្នែកលើ ១០សម ( សូមមើលលេខ ១,២ )

ខ) **បង្គោល/Pole:** ប្រវែង១៥០សម លាបថ្នាំពណ៌២០សមសម្រាប់ពណ៌នីមួយៗ ( មានក្នុងលេខ ៣,៥,៦ )

គ) **បង្គោល/Picket:** ប្រវែង១០០សម លាបថ្នាំពណ៌លឿង១០សម សម្រាប់ដាក់កន្លែងរកឃើញមីនតោន ( សូមមើលលេខ ១០)

ឃ) **បង្គោល/Picket:** ប្រវែង៥០សម លាបថ្នាំពណ៌១០សម សម្រាប់ពណ៌នីមួយៗ (សូមមើលលេខ ៤, ៧, ៨, ៩, ១១, ១២, ១៣, ១៤, ១៥)

ង) **បង្គោលដែក/Metal bar:** ប្រវែង៣០សម ដំចូលក្នុងដី ( សូមមើលលេខ ១៦)

